**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង**
**ខេត្តបន្ទាយមានជ័យ**

សំណុំរឿងព្រហ្មទណ្ឌលេខ : ៣២៦
ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១
ជំនុំជម្រះថ្ងៃទី : ០៩-សីហា-២០២១
សាលក្រមលេខ : **៣៨ "ឈ"/២៤៩**
ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តបន្ទាយមានជ័យ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តបន្ទាយមានជ័យ នាថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង បីរសៀល។

បានប្រកាសសាលក្រមជាសាធារណៈ នាថ្ងៃទី១២ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ប្រាំបួនព្រឹក។

## <u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>

- លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

## <u>តំណាងអយ្យការ</u>

- លោក [redacted] ជាព្រះរាជអាជ្ញារង

## <u>ក្រឡាបញ្ជីសវនាការ</u>

- លោក [redacted] ជាក្រឡាបញ្ជី

## <u>មេធាវី</u>

- លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] តុញ
- លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] តុញ



Scanned with CamScanner

- លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ឈ្មោះ [redacted] ពេត

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៣២៦ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ ដែលមានជនជាប់ចោទដូចខាងក្រោម ៖

១.ឈ្មោះ [redacted] **តុញ** ភេទប្រុស កើតឆ្នាំ១៩៩៧ សញ្ជាតិខ្មែរ ជានីតិជន មុខរបរកសិករ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានមុនពេលឃុំខ្លួនភូមិ[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ[redacted]តេង (រស់) ម្ដាយឈ្មោះ [redacted] សៀង (រស់) ប្រពន្ធឈ្មោះ អូន មានកូនចំនួន ០១នាក់ កម្រិតវប្បធម៌ថ្នាក់ទី១០ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ២៣២ ព្រ.ទ៕-គ-/២១ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១)

២.ឈ្មោះ [redacted] **ពេត ហៅ** [redacted] **ពេត** ភេទប្រុស ០២.១១.១៩៨៣ សញ្ជាតិខ្មែរ ជានីតិជន មុខរបរកសិករ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូ[redacted] ខេត្តបាត់ដំបង អាសយដ្ឋានបច្ចុប្បន្នភូមិល្បើកស្វាយ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ ពីន (រស់) ម្តាយឈ្មោះ សាន (រស់) ប្រពន្ធឈ្មោះ[redacted]រីន ប្រវិត្តនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ (គេចខ្លួន)

ជាប់ចោទពីបទ "**ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន**" តាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ និងពីបទ "**ការមិនបានរាយការណ៍ព័ត៌មានជូនអាជ្ញាធរសមត្ថកិច្ចដែលអាចបង្កឱ្យមានគ្រោះមហន្តរាយ**" តាមបញ្ញត្តិមាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ(ឆ្នាំ២០១៥) ប្រព្រឹត្តនៅភូមិល្បើកស្វាយ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១។

**អង្គហេតុកើតឡើងមានដូចតទៅ** :

កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១ ម៉ោងប្រហែល ០៨:៤០នាទី សមត្ថកិច្ចនគរបាលស្រុកថ្មពួកបានសហការជាមួយនគរបាលវរៈការពារព្រំដែន៩១១ និងយោធាវរៈសេនាតូច៥៣០ បានចេញល្បាតនៅតាមបណ្តោយព្រំដែនខ្មែរ-ថៃ ដល់ចំណុចភូមិល្បើកស្វាយ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ បានជួបនឹងគោយន្តកន្ត្រៃមួយគ្រឿងម៉ាកគូបុតា បើកបរដោយឈ្មោះ [redacted] តុញ ភេទប្រុស និងមេខ្យល់ម្នាក់ទៀតឈ្មោះ [redacted] ពេត ហៅ [redacted]ពេត ភេទប្រុស កំពុងដឹកពលករចំនួន ១៦នាក់ ដែលមកពីខេត្តព្រៃវែង ០៥នាក់ , ខេត្តឧត្តរមានជ័យ ០៧នាក់ និងខេត្តបន្ទាយមានជ័យ ០៤នាក់ បំរុងនឹងនាំឆ្លងដែនចូលទៅក្នុងប្រទេសថៃ ហើយសមត្ថកិច្ចឃាត់ឱ្យឈប់ ស្រាប់តែឈ្មោះ [redacted] ពេត រត់គេចខ្លួនបាត់នៅសល់តែពលករ១៦នាក់ និងឈ្មោះ [redacted] តុញ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន។ ឈ្មោះ [redacted] តុញ បានសារភាពថា ឈ្មោះ [redacted] ពេត ជាអ្នកទាក់ទងជាមួយពលករ ដើម្បីនាំឆ្លងដែន ចំណែកខ្លួនជាអ្នកដើរប្រមូលដឹកទៅព្រំដែន យកកម្រៃថ្លៃដឹកក្នុងចំនួន

១០នាក់ បានប្រាក់៥០០បាត ចំណែកម្រៃនាំឆ្លងដែនមិនដឹងទេ។ សមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនជនល្មើសឈ្មោះ [redacted] តុញ និងវត្ថុតាងមកអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធី។

បានឃើញ : ដីកាសន្និដ្ឋានស្ថាពរលេខ : ២៧៤ អ.យ.យ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១។

បានឃើញ : ដីកាដំណោះស្រាយលេខ : ១៧៥១ ពស.ព្រស-ត-/២១ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០២១។

បានឃើញ : ដីកាចាត់តាំងក្រុមប្រឹក្សាចៅក្រមជំនុំជម្រះលេខ : ៣៥១ ពស.ព្រជ-ក-/២១ ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០២១។

បានឃើញ : ឯកសារនានាក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ : ៣២៦ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១។

បានឃើញ : ការផ្តល់ និងការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ ដែលធ្វើឡើងអនុលោមតាមបញ្ញត្តិមាត្រា ២៩២ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**នាពេលសវនាការ** :

- ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **តុញ**
- ក្រោយពីបាន ពិនិត្យឯកសារ និង ភស្តុតាងនានាដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះ
- ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបាន ស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបាន ពិនិត្យ និងពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងខេត្ត បន្ទាយមានជ័យ**

**យល់ឃើញថា** :

១.តាមរយៈដីកាដំណោះស្រាយ លេខ : ១៧៥១ ពស.ព្រស-ត-/២១ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០២១ របស់ចៅក្រមស៊ើបសួរ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **តុញ** ភេទប្រុស កើតឆ្នាំ១៩៩៧ និងឈ្មោះ [redacted] **ពេត ហៅ** [redacted] **ពេត** ភេទប្រុស កើតថ្ងៃទី០២.១១.១៩៨៣ មកធ្វើការជំនុំជម្រះពីបទ "**ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន**" តាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងពីបទ "**ការមិនបានរាយការណ៍ព័ត៌មានជូនអាជ្ញាធរសមត្ថកិច្ចដែលអាចបង្កឱ្យមានគ្រោះមហន្តរាយ**" តាមបញ្ញត្តិមាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ (ឆ្នាំ២០១៥) ប្រព្រឹត្តនៅភូមិល្បើកស្វាយ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១។

២.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **តុញ** បានឆ្លើយនាពេលសវនាការថា : កាលពីថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ១១:៣០នាទីយប់ សមត្ថកិច្ចបានឃាត់ខ្លួន នៅនឹងចំការស្វាយចន្ទី នៅពេលខ្លួនកំពុងបើកគោយន្តដឹកពលករចំនួន ១៦នាក់ ដើម្បីឆ្លងដែនទៅប្រទេសថៃ តាមច្រកតំបន់១ ដោយដឹកចេញពីខាងភូមិល្បើកស្វាយ ឆ្ពោះទៅចំការស្វាយចន្ទី ពេលដឹកមិនទាន់ឈប់គោយន្តផង ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន។ កន្លងមកខ្លួនធ្លាប់ដឹកពលករឆ្លងដែនទៅប្រទេសថៃ បានចំនួន ១០លើកមកហើយ ក្នុងអំឡុងខែ

មីនា ឆ្នាំ២០២១ ជនបន្តបន្ទាប់តាមច្រកតំបន់មួយៗ ពេលខ្លួនដឹកពលករឆ្លងដែនឈ្មោះ [redacted] ពេត ភេទប្រុស អាយុប្រហែល ៤០ឆ្នាំ រស់នៅភូមិល្បើកស្វាយ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ប្រពន្ធឈ្មោះ [redacted] អិន ម្តាយឈ្មោះ សាន (រស់) ឪពុកឈ្មោះ [redacted] ផ្ទះនៅមុំវត្តល្បើកស្វាយ ជិតស្រះ បានឱ្យខ្លួនដឹកពលករដោយគាត់បានអោយប្រាក់មកអោយខ្លួនក្រោយពេលខ្លួនដឹកពលករហើយ។ សមត្ថកិច្ចបានដកហូតគោយន្តកន្ត្រៃចំនួន០១(មួយ)គ្រឿង និងទូរសព្ទដៃម៉ាកOPPO ពណ៌ក្រហម ចំនួន០១(មួយ)គ្រឿងពីខ្លួន។ នៅក្នុងរឿងនេះខ្លួនសំណូមពរសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផង។ ដែលចម្លើយនេះបង្ហាញឱ្យតុលាការជឿជាក់បាន។

៣.ផ្អែកតាមសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **តុញ** បានឆ្លើយថា ខ្លួនត្រូវបានឈ្មោះ [redacted] ពេត ភេទប្រុស ដែលត្រូវជាមេខ្យល់ជួលខ្លួនឱ្យដឹកកម្មករចំនួន ១៦នាក់ ទៅទុកនៅចម្ការស្វាយចន្ទីនៅភូមិល្បើកស្វាយ ឃុំល្បើកស្វាយ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ក្នុងគោលបំណងទៅធ្វើការនៅប្រទេសថៃ ដោយឈ្មោះ [redacted] ពេត បានឱ្យថ្លៃឈ្នួលដឹកមកខ្លួន ចំនួន ៥០០បាតក្រោយពីដឹករួច តែមិនបានប្រាក់ឈ្នួលឡើយ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួនមិនបាននាំពលករទៅឆ្លងដែនចូលប្រទេសថៃទេ គឺខ្លួនគ្រាន់តែស៊ីឈ្នួលដឹកឱ្យឈ្មោះ [redacted] ពេត តែប៉ុណ្ណោះ។ ចម្លើយនេះមានលក្ខណៈច្បាស់លាស់អាចឱ្យតុលាការជឿជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] តុញ មិនបាននាំយកមនុស្សចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែនឡើយ ក៏ប៉ុន្តែជនជាប់ចោទឈ្មោះ [redacted] តុញ បានស៊ីឈ្នួលដឹកពលករឱ្យឈ្មោះ [redacted] ពេត យកមកទុកនៅកន្លែងចម្ការស្វាយចន្ទី តាមការបង្គាប់បញ្ជារបស់ឈ្មោះ [redacted] ពេត ដើម្បីងាយស្រួលសម្រួលឱ្យឈ្មោះ [redacted] ពេត នាំពលករឆ្លងដែនចូលទៅធ្វើការនៅប្រទេសថៃ។ ស្របតាមស្មារតីនៃនិយមមាត្រា ២០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចែងថា "**ជនណាដែលទទួល ផ្តល់ជម្រក ឬលាក់បំពួនជនរងគ្រោះក្នុងអំពើនាំយកចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់ ដូរ ឬ ដឹកជញ្ជូន ក្នុងគោលដៅដើម្បីជួយដល់ជនល្មើស ដែលបាននាំយកចេញដោយមិនស្របច្បាប់ ជ្រើសរើសលក់ដូរ ឬដឹកជញ្ជូនជនរងគ្រោះ**" នេះគឺជាអំពើ "**ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស**" អំពើប្រព្រឹត្តរបស់ជនជាប់ចោទបានសរបញ្ជាក់ឱ្យតុលាការឃើញថា ជនជាប់ចោទឈ្មោះ [redacted] តុញ ពិតជាបានប្រព្រឹត្តបទល្មើស "**ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស**" ប្រាកដមែន។ ដូចនេះគប្បីតុលាការកែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] តុញ ភេទប្រុស ពីបទ "**ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន**" តាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីកម្មផ្លូវភេទ **មកជាបទ "ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស"** តាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីកម្មផ្លូវភេទ វិញ។

៤.តាមរយៈទង្វើ និងសកម្មភាពរបស់ជនជាប់ចោទ បានបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទត្រូវបានឈ្មោះ [redacted] ពេត ហៅ [redacted] ពេត ជួលឱ្យដឹកជនរងគ្រោះយកមកទុកក្នុងគោលបំណងដើម្បីឱ្យឈ្មោះ [redacted] ពេត ហៅ [redacted] ពេត យកជនរងគ្រោះឆ្លងដែនទៅប្រទេសថៃ ហើយការដឹកនេះពុំមានការបង្ខិតបង្ខំពីជនរងគ្រោះ ឬក៏ជនជាប់ចោទឈ្មោះ [redacted] ពេត ហៅ [redacted] ពេត នោះឡើយ នេះអាចបង្ហាញឱ្យតុលាការឃើញថា ជនជាប់ចោទ

ឈ្មោះ [redacted] តុញ ពុំមានគោលដៅនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងគោលដៅប្រគល់ ឬនាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា នោះទេ ដែលពុំមានធាតុផ្សំគ្រប់គ្រាន់នៃបទល្មើស **"ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន"** ដូចមានចែងតាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នោះឡើយ ប៉ុន្តែសកម្មភាពរបស់ជនជាប់ចោទបានស្តែងចេញឱ្យឃើញថា អំពើរបស់ជនជាប់ចោទដែលបានប្រព្រឹត្ត គឺមានចេតនាទុច្ចរិត ក្នុងការដឹកជញ្ជូនជនរងគ្រោះដោយមានគោលដៅ ដើម្បីឱ្យជនជាប់ចោទឈ្មោះ [redacted] ពេត ហៅ [redacted] ពេត បាននាំជនរងគ្រោះឆ្លងដែនចូលទៅប្រទេសថៃ ដូចនេះគប្បីតុលាការចោទប្រកាន់លើជនជាប់ចោទឈ្មោះ **"ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស"** តាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីកម្មផ្លូវភេទ វិញ។

៥.តាមរយៈសកម្មភាព និងភស្តុតាងផ្សេងៗរបស់ជនជាប់ចោទដែលបានប្រព្រឹត្ត មានលក្ខណៈច្បាស់លាស់ស៊ីសង្វាក់ទៅនឹងរបាយការណ៍ស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងផ្សេងៗដែលមានក្នុងសំណុំរឿង អាចធ្វើឱ្យតុលាការជឿជាក់បានថា ពិតជាមានករណីនៃអង្គហេតុ **"ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស"** តាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងពីបទ **"ការមិនបានរាយការណ៍ព័ត៌មានជូនអាជ្ញាធរសមត្ថកិច្ចដែលអាចបង្កឱ្យមានគ្រោះមហន្តរាយ"** តាមបញ្ញត្តិមាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ(ឆ្នាំ២០១៥) ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] **តុញ** ប្រាកដមែន។

៦.ថ្វីត្បិតតែជនជាប់ចោទឈ្មោះ [redacted] ពេត ហៅ [redacted] ពេត មិនបានចូលខ្លួននៅចំពោះមុខតុលាការក៏ពិតមែន ប៉ុន្តែផ្អែកទៅលើចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] តុញ និងរបាយការណ៍ស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងភស្តុតាងជាឯកសារពាក់ព័ន្ធផ្សេងៗ បានបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] ពេត ហៅ [redacted] ពេត ពិតជាមេខ្យល់នាំមនុស្សឆ្លងដែនប្រាកដមែន។

៧.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា : ផ្អែកទៅលើចម្លើយសារភាពរបស់ជនជាប់ចោទ , និងភស្តុតាងផ្សេងៗដែលមាននៅក្នុងសំណុំរឿង សរបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] តុញ ពិតជាមិនមែនមេខ្យល់នាំយកមនុស្សឆ្លងដែនចូលទៅធ្វើការនៅប្រទេសថៃឡើយ ក៏ប៉ុន្តែជនជាប់ចោទឈ្មោះ [redacted] តុញ បានស៊ីឈ្នួលដឹកពលករឱ្យជនជាប់ចោទឈ្មោះ [redacted] ពេត ហៅ [redacted] ពេត ដែលត្រូវជាមេខ្យល់យកមកទុកដើម្បីឱ្យឈ្មោះ [redacted] ពេត ហៅ [redacted] ពេត ងាយស្រួលនាំមនុស្សឆ្លងដែនចូលទៅប្រទេសថៃ ប្រាកដមែន សូមកែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] តេញ ពីបទ **"ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន"** តាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីកម្មផ្លូវភេទ **មកជាបទ "ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស"** តាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីកម្មផ្លូវភេទ វិញ ។ ចំណែកឯជនជាប់ចោទឈ្មោះ [redacted] ពេត ហៅ [redacted] ពេត សូមរក្សាបទចោទប្រកាន់ដដែលតាមដីកាសន្និដ្ឋានស្ថាពរ និងប្តឹងសុំឱ្យលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនទាំងនេះទៅតាមច្បាប់ ជាការសន្និដ្ឋានគប្បីពិចារណា។



Scanned with CamScanner

៨.លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **តុញ** បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីរបស់ខ្លួនមានបានស៊ីឈ្នួលដឹកកម្មករឱ្យទៅឈ្មោះ [redacted] ពេត ហៅ [redacted] ពេត ដែលត្រូវជាមេខ្យល់តែប៉ុណ្ណោះ គឺគ្មានធាតុផ្សំនៃបទល្មើសមិនអាចចោទប្រកាន់ពីបទ **"ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន"** ឡើយ ខ្លួនសំណូមសុំឱ្យលោកប្រធានក្រុមប្រឹក្សាមេត្តាឱ្យកូនក្តីរបស់ខ្លួនរួចខ្លួនពីបទចោទប្រកាន់នេះផង ដោយរក្សាទុកនូវបទចោទ **"ការមិនបានរាយការណ៍ព័ត៌មានជូនអាជ្ញាធរសមត្ថកិច្ចដែលអាចបង្កឱ្យមានគ្រោះមហន្តរាយ"** នេះដដែល គប្បីតុលាការនឹងលើកយកមកពិនិត្យ និងពិចារណាតាមផ្លូវច្បាប់។

៩.លោក **មាច់ សំអន** មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ពេត ហៅ** [redacted] **ពេត** បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ដោយហេតុថាចម្លើយរបស់ឈ្មោះ [redacted] តុញ ពុំមានភស្តុតាងណាមួយបញ្ជាក់ថាកូនក្តីខ្លួនឈ្មោះ [redacted] ពេត ហៅ [redacted] ពេត ជួលឱ្យឈ្មោះ [redacted] តុញ ដឹកកម្មករនោះឡើយ ចម្លើយរបស់ឈ្មោះ [redacted] តុញ ពុំមានឯកសារទំនាក់ទំនង ឬភស្តុតាងអ្វីជាក់លាក់ឱ្យច្បាស់លាស់ ក្នុងការទំលាក់កំហុសមកលើកូនក្តីរបស់ខ្លួននោះទេ ខ្លួនសំណូមសុំឱ្យលោកប្រធានក្រុមប្រឹក្សាមេត្តាឱ្យកូនក្តីរបស់ខ្លួនរួចខ្លួនពីបទចោទប្រកាន់នេះផង ក៏ប៉ុន្តែមានតែចម្លើយសន្និដ្ឋានការពាររបស់មេធាវីតែមួយគត់ដែលចម្លើយមិនអាចយកមកធ្វើជាភស្តុតាងដោះបន្ទុក ឬដើម្បីឱ្យតុលាការជឿជាក់បាននោះទេ។

១០.មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **តុញ** ភេទប្រុស កើតឆ្នាំ១៩៩៧ ពីបទ **"ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស"** តាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងពីបទ **"ការមិនបានរាយការណ៍ព័ត៌មានជូនអាជ្ញាធរសមត្ថកិច្ចដែលអាចបង្កឱ្យមានគ្រោះមហន្តរាយ"** តាមបញ្ញត្តិមាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ(ឆ្នាំ២០១៥) ប្រព្រឹត្តនៅភូមិល្បើកស្វាយ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១។

១១.មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **ពេត ហៅ** [redacted] **ពេត** ភេទប្រុស កើតឆ្នាំ១៩៨៣ ពីបទ **"ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន"** តាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងពីបទ **"ការមិនបានរាយការណ៍ព័ត៌មានជូនអាជ្ញាធរសមត្ថកិច្ចដែលអាចបង្កឱ្យមានគ្រោះមហន្តរាយ"** តាមបញ្ញត្តិមាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ(ឆ្នាំ២០១៥) ប្រព្រឹត្តនៅភូមិល្បើកស្វាយ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១។

១២.ជនជាប់ចោទឈ្មោះ [redacted] **តុញ** ជានីតិជន ពុំមានសញ្ញាណណាមួយបញ្ជាក់ថាជនជាប់ចោទមានបញ្ហាខាងស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសនោះទេ ហើយអំពើរបស់ជនជាប់ចោទដែលបានប្រព្រឹត្តបានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងច្បាប់សង្គម ដែលច្បាប់បញ្ញត្តិឱ្យផ្តន្ទាទោសព្រហ្មទណ្ឌជាធរមាន។

១៣.ជនជាប់ចោទឈ្មោះ [redacted] **តុញ** មានជីវភាពក្រីក្រលំបាក មានចំណេះដឹងតិចតួច មានភាពល្ងង់ខ្លៅ ខ្វះការពិចារណាមួយពេល ហើយទើបប្រព្រឹត្តបទល្មើសជាលើកទី១ ម្យ៉ាងទៀតបន្ទាប់ពីជាប់ពន្ធនាគារ



Scanned with CamScanner

ជនជាប់ចោទមានស្មារតីភ្ញាក់រលឹកដឹងកំហុសរបស់ខ្លួន ដែលបានប្រព្រឹត្ត ហើយមានសោកស្តាយនូវទង្វើរបស់ខ្លួនដែលបានប្រព្រឹត្ត គប្បីតុលាការផ្តល់ស្ថានសម្រាលទោសដល់ជនជាប់ចោទដោយផ្អែកតាមបញ្ញត្តិមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌ។

**១៤.វត្ថុតាងដែលដកហូតមាន** : ទូរសព្ទចំនួន ០១គ្រឿងម៉ាក OPPO ពណ៌ឈាមជ្រូក លេខម៉ូដែល CpH1909 ដែលបានដកហូតពីឈ្មោះ [redacted] **តុញ** រក្សាទុកនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តបន្ទាយមានជ័យ **គប្បីរឹបអូស** ។

១៥.ក្រោយពីបានប្រព្រឹត្តបទល្មើសរួចជនជាប់ចោទឈ្មោះ [redacted] **ពេត ហៅ** [redacted] **ពេត** បានរត់គេចខ្លួនពីការទទួលខុសត្រូវចំពោះមុខច្បាប់ គប្បីតុលាការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនដើម្បីយកមកអនុវត្តទោសតាមច្បាប់ ។

## <u>ហេតុដូចនេះសម្រេច</u>

I. **ផ្តន្ទាទោសជនជាប់ចោទ** :

១.ឈ្មោះ [redacted] **តុញ** ភេទប្រុស កើតឆ្នាំ១៩៩៧ សញ្ជាតិខ្មែរ ជានីតិជន មុខរបរកសិករ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ [redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានមុនពេលឃុំខ្លួន ភូមិ [redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] តេង (រស់) ម្តាយឈ្មោះ [redacted] សៀង (រស់) ប្រពន្ធឈ្មោះ **អួន** មានកូនចំនួន ០១នាក់ កម្រិតវប្បធម៌ថ្នាក់ទី១០ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ (ក្នុងឃុំ)

(ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ : ២៣២ ព្រ.ទ៣"គ"/២១ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១)

**ដាក់ពន្ធនាគារកំណត់រយៈពេល ០២(ពីរ)ឆ្នាំ តែត្រូវអនុវត្តទោសពន្ធនាគាររយៈពេល (ប្រាំបី)ខែ ទោសដែលនៅសល់ត្រូវព្យួរធម្មតាមមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។ ពីបទ "ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស"** តាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងពីបទ **"ការមិនបានរាយការណ៍ព័ត៌មានជូនអាជ្ញាធរសមត្ថកិច្ចដែលអាចបង្កឱ្យមានគ្រោះមហន្តរាយ"** តាមបញ្ញត្តិមាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ(ឆ្នាំ២០១៥) ប្រព្រឹត្តនៅភូមិល្បើកស្វាយ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១។

២.ឈ្មោះ [redacted] **ពេត ហៅ** [redacted] **ពេត** ភេទប្រុស កើតឆ្នាំ១៩៨៣ សញ្ជាតិខ្មែរ ជានីតិជន មុខរបរកសិករ សាសនាព្រះពុទ្ធ ទីកន្លែងកំណើ [redacted] ខេត្តបាត់ដំបង អាសយដ្ឋានបច្ចុប្បន្នភូមិល្បើកស្វាយ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ ពឹន (រស់) ម្តាយឈ្មោះ សាន (រស់) ប្រពន្ធឈ្មោះ [redacted] អ៊ិន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ (គេចខ្លួន)

**ដាក់ពន្ធនាគារកំណត់រយៈពេល ០៨(ប្រាំបី)ឆ្នាំ ពីបទ "ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន"** តាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងពីបទ **"ការមិនបានរាយការណ៍ព័ត៌មានជូនអាជ្ញាធរសមត្ថកិច្ចដែលអាចបង្កឱ្យមានគ្រោះមហន្តរាយ"** តាមបញ្ញត្តិមាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ(ឆ្នាំ២០១៥) ប្រព្រឹត្តនៅភូមិល្បើកស្វាយ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១។



Scanned with CamScanner

II. **វត្ថុតាងដែលដកហូតបាន** : ទូរសព្ទចំនួន ០១គ្រឿងម៉ាក OPPO ពណ៌ឈាមជ្រូក លេខម៉ូដែល CpH1909 ដែលបានដកហូតពីឈ្មោះ [redacted] **ឥញ្ញ** រក្សាទុកនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តបន្ទាយមានជ័យ **ត្រូវរឹបអូស** ។

III. ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] **ពេត ហៅ** [redacted] **ពេត** ដោយផ្អែកតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

IV. សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ឥញ្ញ** និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **ពេត ហៅ** [redacted] **ពេត** ។

បើកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់របស់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ៤កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១
**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner